# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៥៨...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាសភាពក្រុមការងាររបស់ក្រសួងយុត្តិធម៌ ក្នុងការងារនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការនិរាករណ៍អនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើត និង ការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

# សម្រេច

**មាត្រា១** : ត្រូវបានតែងតាំងសមាសភាពនៃ "ក្រុមការងាររបស់ក្រសួងយុត្តិធម៌ ក្នុងការងារនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម" ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | អង្គ វង្សវឌ្ឍានា | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ប្រធាន |
| ២- ឯកឧត្តម | ឡុង ផុល | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣- ឯកឧត្តម | ហែម ក្រាញ់ តូនី | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៤- ឯកឧត្តម | ចំន្ទ មនោ | ទីប្រឹក្សាអមក្រសួងយុត្តិធម៌ និងជានាយកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ៥- លោក | ជីវ កេង | ប្រធានតុលាការក្រុងភ្នំពេញ | សមាជិក |
| ៦- លោក | ម៉ុង មុន្នីចរិយា | ចៅក្រមតុលាការកំពូល | សមាជិក |
| ៧- លោក | ម៉ែន ពេជ្រសាលី | ចៅក្រម និងជាប្រធាននាយកដ្ឋានកិច្ចការអន្តរជាតិ ក្រសួងយុត្តិធម៌ | សមាជិក |
| ៨- លោក | ប៊ុនយ៉ៃ ណារិន | អធិការ និងជានាយខុទ្ទកាល័យរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ | សមាជិក |

**មាត្រា២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៦*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ-កាលប្បវត្តិ*